# អភិបាលកិច្ចមូលដ្ឋានលើធនធានទ្រព្យរួមៈ ករណីសិក្សាពីធារាសាស្ត្រនៅកម្ពុជា*

## សេចក្ដីផ្ដើម

ធនធានទ្រព្យរួម គឺជាធនធានដូចជា ព្រៃឈើ ត្រី ទឹក និងវាលស្មៅ ដែលពុំចាំបាច់ផលិតវាមកទេ និងជាប្រភពចម្បងនៃអាហារប្រចាំថ្ងៃ និងប្រាក់ចំណូលសម្រាប់ជនក្រីក្រនៅជនបទ ។ គេតែងយល់ថា ធនធានទាំងនេះស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋ ដែលជាអង្គភាពមួយមើលមិនឃើញទេ និងដែលតាំងពីដើមរៀងមក បើតាមឯកសារជាតិ និងអន្តរជាតិនានា គឺជាស្ថាប័នអរូបីមួយដែលមិនបានគ្រប់គ្រងយ៉ាងសមស្រប ឬក៏មិនបានគ្រប់គ្រងទាល់តែសោះ នូវធនធានទាំងនេះ (Berkes ១៩៨៩) ។ ស្ថានភាពនេះធ្វើឱ្យកើតមានករណីទូទៅ ២ ។ ករណីទី១ គឺប្រជាពលរដ្ឋម្នាក់ៗ ហាក់ដូចជា មានសិទ្ធិប្រើប្រាស់ និងទាញយកផលពីធនធានទាំងនេះដោយសេរី និងគ្មានច្បាប់គ្រប់គ្រងអ្វីទេ (Ostrom ១៩៩០, ១៩៩២, ១៩៩៩) ។ ករណីទី២ គឺអ្នកមានទ្រព្យ និងមានអំណាច អាចប្រើប្រាស់ធនធានទាំងនេះ សម្រាប់ជាប្រយោជន៍ផ្ទាល់ខ្លួន និងថែមទាំងមិនអនុញ្ញាតអោយប្រជាជនក្រីក្រទាញយកផលអ្វីទៀតផង ។ ទោះជាករណីទី១ រឺករណីទី២ ក្ដីក៏ជារឿយៗវានាំឱ្យធនធានត្រូវហិនហោច ឬបាត់បង់ទាំងស្រុង ។

> **ប្រទេសកម្ពុជាមានធនធានធម្មជាតិ យ៉ាងសំបូរ និងកំពុងប្រឹងប្រែងអភិវឌ្ឍសេដ្ឋកិច្ច ជាពិសេសជីវភាពរស់នៅរបស់ប្រជាជន ប៉ុន្តែខ្វះខាតជាខ្លាំងនូវគោលនយោបាយដ៏ប្រសើរមួយ សំរាប់គ្រប់គ្រងធនធានឱ្យមានចីរភាព និងមានការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព ។**

ប្រទេសកម្ពុជា មានធនធានធម្មជាតិយ៉ាងសំបូរ និងកំពុងប្រឹងប្រែងអភិវឌ្ឍសេដ្ឋកិច្ច ជាពិសេសជីវភាពរស់នៅរបស់ប្រជាជន ប៉ុន្តែខ្វះខាតជាខ្លាំងនូវគោលនយោបាយដ៏ប្រសើរមួយ សំរាប់គ្រប់គ្រងធនធានឱ្យមានចីរភាព និងមានការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព ។ ដោយមើលឃើញពីតំរូវការនេះ កម្មវិធីអភិបាលកិច្ច នៃវិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា បានសម្រេចចិត្តធ្វើការសិក្សាលើចំនុចនេះ ដើម្បីស្វែងយល់ពីកត្តាផ្សេងៗ ដែលជួយសំរួល រឺរារាំងអភិបាលកិច្ចល្អលើធនធានទ្រព្យរួមនៅកម្ពុជា ជាពិសេសធនធានទឹក ដែលជាកត្តាស្នូលសំរាប់ការអភិវឌ្ឍន៍កសិកម្មនាពេលបច្ចុប្បន្ន ។

គម្រោងនេះបានសិក្សាលំអិតពីឌីណាមិក នៃវិធីសាស្ត្រពីរ ក្នុងការគ្រប់គ្រងទឹកស្រោចស្រព ។ វិធីសាស្ត្រទី១ គឺការគ្រប់គ្រងធនធានធម្មជាតិផ្អែកលើសហគមន៍ (CBNRM) និងវិធីសាស្ត្រទី២ គឺវិមជ្ឈការក្នុងការគ្រប់គ្រងធនធានធម្មជាតិ (DNRM) ។ វិធីសាស្ត្រទាំងពីរនេះ ជាប់ទាក់ទងនឹងគោលនយោបាយថ្នាក់ជាតិពីរ គឺគោលនយោបាយទឹក និងវិមជ្ឈការ ។ ក្នុងគោលនយោបាយទឹក វិធីសាស្ត្រផ្អែកលើសហគមន៍ បានប្រគល់ការទទួលខុសត្រូវ ក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រជាក់លាក់ណាមួយ ទៅឱ្យសហគមន៍កសិករអ្នកប្រើប្រាស់ទឹក (FWUC) តំណាងដោយសមាគមមួយមានថ្នាក់ដឹកនាំជ្រើសតាំងឡើងតាមការបោះឆ្នោត ចំណែកឯវិធីសាស្ត្រវិមជ្ឈការ បានផ្ដល់ឱ្យក្រុមប្រឹក្សាឃុំសង្កាត់ ដែលជាប់ឆ្នោត នូវសិទ្ធិគ្រប់គ្រងធនធានធម្មជាតិនៅក្នុងដែនដីរបស់ខ្លួន រួមទាំងធនធានទឹកផង ។ ការសិក្សានេះ មានគោលបំណងស្វែងយល់ពី ស្ថានភាពក្នុងសហគមន៍មូលដ្ឋាន ដែលមានការអនុវត្តគោលនយោបាយ ឬការផ្ទេរមុខងារត្រួតស៊ីគ្នាទាំងពីរនេះ ។ ការសិក្សាស្រាវជ្រាវនេះបានចោទសួរថា តើវិធីសាស្ត្រនីមួយៗ ជះឥទ្ធិពលដោយឯករាជ្យយ៉ាងដូចម្ដេចទៅលើការគ្រប់គ្រងទឹកស្រោចស្រពក្នុងមូលដ្ឋាន ហើយអន្តរកម្មនៃវិធីសាស្ត្រទាំងពីរ វារួមចំណែកយ៉ាងដូចម្ដេចក្នុងការងារគ្រប់គ្រងទាំងមូល ។

ការសិក្សានេះ មានគោលបំណងសំខាន់ៗពីរៈ ១. សិក្សាពីដំណើរការដើម្បីកំណត់ពីផលប៉ះពាល់ខាងគោលនយោបាយ និងលើកជាអនុសាសន៍ និង ២. រួមចំណែកកសាងឯកសារ ស្ដីពីអភិបាលកិច្ចធនធានទ្រព្យរួម ។

## វិធីសាស្ត្រស្រាវជ្រាវ

ផ្អែកលើគោលបំណងនៃការសិក្សា អ្នកស្រាវជ្រាវបានសិក្សាលើឯកសារជាតិ និងអន្តរជាតិ ដើម្បីកំណត់នូវ អថេរនានាដែលត្រូវពិនិត្យតាមដានដល់មូលដ្ឋាន ។ បន្ទាប់មក អ្នកស្រាវជ្រាវត្រូវប្រៀបធៀបក្របខ័ណ្ឌការសិក្សាដែលទទួលបានពីការសិក្សាឯកសារ ទៅនឹងទិន្នន័យអង្កេតនៅកន្លែង ។ សហគមន៍កសិករធ្វើស្រែប្រាំង ដែលពឹងផ្អែកលើប្រព័ន្ធធារាសាស្ត្រមួយក្នុងខេត្តកំពង់ឆ្នាំង ត្រូវបានជ្រើសរើសជា ករណីសិក្សានៃការគ្រប់គ្រងទឹកស្រោចស្រពក្នុងមូលដ្ឋាន តាំងតែពីពេលរបបខ្មែរក្រហមបានដួលរលំមក ។

## លទ្ធផលសំខាន់ៗ

ករណីសិក្សាបានបង្ហាញថា វិធីសាស្ត្រ DNRM ត្រូវបានអនុវត្តនៅកម្ពុជាតាំងពីចុងទសវត្សរ៍ ១៩៨០ និងដើមទសវត្សរ៍ ១៩៩០ ។ ទោះបីដោយចៃដន្យ ឬដោយការរៀបចំក្ដី ក៏ការគ្រប់គ្រងធារាសាស្ត្រ គឺជាការទទួលខុសត្រូវរបស់មេឃុំ ដែលទទួលបានជំនួយបច្ចេកទេស និងធនធានអភិវឌ្ឍន៍

* ដោយអ្នកស្រី ជា ជូ ជាអ្នកស្រាវជ្រាវ នៃវិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ។ អត្ថបទនេះ សង្ខេបនូវលទ្ធផលនៃគម្រោងស្រាវជ្រាវមួយក្នុងកម្មវិធីកែច្នៃរបស់ផ្នែកអភិបាលកិច្ចនៃ វបសអ ។ អត្ថបទសិក្សាទាំងមូលលើប្រធានបទនេះ នឹងមានចុះនៅលើវេបសាយរបស់ វបសអ នាពេលឆាប់ៗនេះ ។

ខ្លះពីមន្ទីរខេត្ត និងដែលមានភារកិច្ចប្រមែប្រមូលប្រជាពលរដ្ឋក្នុងមូលដ្ឋាន ដើម្បីកសាងសំណង់គ្រប់គ្រងទឹក និងជួយត្រួតពិនិត្យការសាងសង់ និងការគ្រប់គ្រង ។ ករណីសិក្សាបានបង្ហាញថា តួអង្គរដ្ឋអំណាចនៅមូលដ្ឋានដែលសំខាន់ៗជាងគេ ក្នុងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រនៅអំឡុងពេលនេះ រួមមាន មេឃុំ មេភូមិ និងភ្នាក់ងារពង្រឹងអនុវត្តន៏ច្បាប់ ។ ទោះបីជាការគ្រប់គ្រងនៅពេលនេះ បង្ហាញពីលក្ខណៈមជ្ឈការនៃប្រព័ន្ធរដ្ឋ ប៉ុន្តែឃុំមិនអាចគ្រប់គ្រងធនធានប្រកបដោយប្រសិទ្ធភាពឡើយ ពីព្រោះឃុំមិនមានធនធានផ្ទាល់ និងជាប់រវល់កិច្ចការនយោបាយ ដូចជាការប្រមូលប្រជាពលរដ្ឋឱ្យចូលបម្រើក្នុងកម្មវិធីក៥ ជាដើម ។

ដើម្បីឆ្លើយតបនឹងសំណើរបស់ សហគមន៏អ្នកផ្តល់ជំនួយដែលក្តោបក្តាប់ទឹកប្រាក់អភិវឌ្ឍន៏នៅទសវត្សរ៏ ១៩៩០ មានការផ្លាស់ប្តូរពី DNRM ទៅរក CBNRM ដោយមានសហគមន៏កសិករអ្នកប្រើប្រាស់ទឹក (FWUC) ត្រូវបានកំណត់ចេញជាផ្លូវការ និងសមាគមក្នុងមូលដ្ឋានមួយដែលរដ្ឋឺអង្គការមិនមែនរដ្ឋភិបាលបានរៀបចំឡើង ដើម្បីធ្វើជាតំណាងរបស់សហគមន៏ ។ វិធីសាស្ត្រ CBNRM ដែលមានខ្សែរយៈគ្រប់គ្រងពីលើចុះក្រោមនេះ ត្រូវបានផ្សព្វផ្សាយទូទាំងប្រទេសនៅចុងទសវត្សរ៏ ១៩៩០ នៅពេលគោលនយោបាយអភិវឌ្ឍន៏ និងការគ្រប់គ្រងធារាសាស្ត្រដោយមានការចូលរួមត្រូវបានអនុម័តនៅថ្នាក់ជាតិ ។

តាំងពីដើមឆ្នាំ២០០២ ការគ្រប់គ្រងទឹកស្រោចស្រពនៅមូលដ្ឋាន បានប្រើជាមួយគ្នានូវ CBNRM និង DNRM ហើយទាំងពីរនេះ បានដាក់បញ្ចូលជាផ្លូវការទៅក្នុងគោលនយោបាយជាតិគ្រប់គ្រងវិស័យនេះ ។

ទោះបីជាការគ្រប់គ្រងនៅពេលនេះ
បង្ហាញពីលក្ខណៈមជ្ឈការនៃប្រព័ន្ធរដ្ឋ
ប៉ុន្តែឃុំមិនអាចគ្រប់គ្រងធនធាន
ប្រកបដោយប្រសិទ្ធភាពឡើយ
ពីព្រោះឃុំមិនមានធនធានផ្ទាល់
និងជាប់រវល់កិច្ចការនយោបាយ ។

**ការរួមចំណែកនៃ** CBNRM

ក្នុងវិធីសាស្ត្រនេះ អភិបាលកិច្ចល្អមានលក្ខណៈសំគាល់ពីរ ។ ទីមួយ គឺ FWUC មានលក្ខណៈឆ្លើយតបល្អជាងប្រព័ន្ធរដ្ឋ ចំពោះតម្រូវការអភិវឌ្ឍន៏របស់សហគមន៏មូលដ្ឋាន ។ ជាក់ស្តែង FWUC បានពង្រីកប្រព័ន្ធធារាសាស្ត្រតាមរយៈការកសាងស្ពាន និងផ្លូវទៅកាន់ទ្វារទឹក ដើម្បីសម្រួលដល់ការដឹកជញ្ជូនស្រូវ ដែលចោទបញ្ហាជាច្រើនទសវត្សរ៏មកហើយៗ ដែលអាជ្ញាធរមូលដ្ឋានមិនបានដោះស្រាយ ។ ទីពីរ គឺ FWUC អាចរកឃើញបញ្ហាយ៉ាងឆាប់ និងផ្តល់ដំណោះស្រាយទាន់ពេល ដូចជានៅពេលចាត់ចែងការកសាងផ្លូវឆ្លងកាត់ដីរបស់កសិករជាច្រើននាក់នៅក្នុងមូលដ្ឋាន ។ សហគមន៏បានកត់សម្គាល់យ៉ាងឆាប់នូវ បញ្ហាកសិករមិនព្រមលះបង់ដីដោយគ្មានសំណង ។ ដូច្នេះ FWUC ក៏បានលើកសំណើទៅឃុំឱ្យយកដីឃុំខ្លះទៅដោះដូរជាមួយកសិករ ដើម្បីអាចដំណើរការសាងសង់ផ្លូវ ដែលអាចជួយដោះស្រាយបញ្ហាដឹកជញ្ជូនស្រូវសំរាប់សហគមន៏ទាំងមូល ។ ទោះបីគំនិតផ្តួចផ្តើមរបស់សហគមន៏មិនបានផ្តល់ដំណោះស្រាយភ្លាមៗ សំរាប់បញ្ចប់បញ្ហាក្តី ប៉ុន្តែករណីនេះបានបង្ហាញថា FWUC មានការយល់ដឹង និងចំណេះដឹងយ៉ាងទូលំទូលាយពីបរិបទនៅមូលដ្ឋាន ។

*ការរួមចំណែកនៃ DNRM*

តាំងពីពេលចាប់អនុវត្ត CBNRM មក តួនាទីរបស់រដ្ឋអំណាចមូលដ្ឋានត្រូវបានកាត់បន្ថយមកត្រឹមអន្តរាគមន៏ផ្សេងៗ តាមការស្នើសុំរបស់ FWUC (ឧទាហរណ៏ នៅពេលមានវិបត្តិ ដូចជាកង្វះទឹកនៅដើមឆ្នាំ២០០៦ និងដើមឆ្នាំ២០០៧) ។ ស្ថានភាពនេះនៅដដែល ទោះបីគោលនយោបាយវិមជ្ឈការនៅឆ្នាំ ២០០២ បានផ្តល់សិទ្ធិអំណាចជា រដ្ឋអំណាចឯករាជ្យថ្នាក់មូលដ្ឋានទៅដល់ក្រុមប្រឹក្សាឃុំសង្កាត់ក៏ដោយ ។ ជាទូទៅ ទោះបីគេចាត់ទុកឃុំជាអង្គភាពមូលដ្ឋាន ដែលមានអំណាចគ្រប់គ្រាន់អាចបញ្ជាឱ្យប្រជាពលរដ្ឋក្នុងមូលដ្ឋានប្រតិបត្តិតាមបានក្តី ប៉ុន្តែការគ្រប់គ្រងទឹកស្រោចស្រពស្ថិតក្រោមការក្តោបក្តាប់របស់ FWUC ដោយមានការគាំទ្រម្តងម្កាល គឺក្រោមរូបភាពជាការជួយធ្វើអន្តរាគមន៏របស់ក្រុមប្រឹក្សាឃុំសង្កាត់ ។

**កត្តារារាំង និងកត្តាជំរុញដល់អភិបាលកិច្ចមូលដ្ឋានលើធនធានទ្រព្យរួមនាពេលបច្ចុប្បន្ន**

គេបានរកឃើញកត្តាគន្លឹះចំនួនបី ដែលមានឥទ្ធិពលលើការគ្រប់គ្រងទឹក ស្រោចស្រពនៅមូលដ្ឋាន គឺ មានការចូលរួមរបស់សហគមន៏ភាពជាម្ចាស់របស់សហគមន៏ និងសិទ្ធិអំណាច ឬការត្រួតត្រារបស់សហគមន៏ ។

ការចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋាននៅក្នុងការងារសហគមន៏ ដែលជាយន្តការគន្លឹះជំរុញជោគជ័យនៃ ដំណើរការ CBNRM វាមានកំរិតនៅឡើយនៅក្នុងតំបន់សិក្សា ។ រឿងនេះ ដែលឃើញមានដំណើរការម្តងម្កាលដែរនៅក្នុងសហគមន៏ សព្វថ្ងៃត្រូវរាំងស្ទះដោយកត្តាជាច្រើន ។ ទីមួយ គឺ ដំណើរការបែបពីលើចុះក្រោមនៃ CBNRM មិនទាន់អនុវត្តបានពេញលេញទេនូវការងាររៀបចំសហគមន៏ និងផ្តល់សិទ្ធិអំណាច ។ វិធីសាស្ត្រផ្តួចផ្តើមឡើងដោយរដ្ឋនេះ ដំបូងឡើយសង្កត់ធ្ងន់លើការបង្កើតសមាគមតាមរយៈការបោះឆ្នោតមួយដង ដោះស្រាយបានសព្វគ្រប់[1] ដើម្បីតំណាងឱ្យសហគមន៏ និងការបណ្តុះបណ្តាលថ្នាក់ដឹកនាំ ២-៣នាក់ ក្នុងសហគមន៏ពីវិធីសាស្ត្រ CBNRM និងពីវិធីដំណើរការសមាគម ។ ការអនុវត្តបែបនេះបានបំភ្លេចចោលនូវសារៈសំខាន់នៃការផ្តល់សិទ្ធិអំណាច ឱ្យសមាជិកសហគមន៏ ដែលជាកត្តាស្នូលសំរាប់ដំណើរការនេះ ដើម្បីឱ្យគេយល់ដឹងពី

១ គេសង្កេតឃើញថា មានការបោះឆ្នោតក្នុងសហគមន៏តែមួយលើកប៉ុណ្ណោះនៅឆ្នាំ២០០០ ហើយតាំងពីពេលនោះមក សមាគមមិនដែលបានបន្តអាណត្តិ ៣ឆ្នាំ របស់ខ្លួនទៀតទេ ។

សិទ្ធិអំណាចរបស់ខ្លួន ហើយចូលរួមក្នុងការកសាងបទបញ្ញត្តិផ្សេងៗ ការអនុវត្តបទបញ្ញត្តិ និងការពង្រឹងអនុវត្តបទបញ្ញត្តិនៅក្នុងសហគមន៍ ញ៉ាំងឱ្យដំណើរការមានការយកចិត្តទុកដាក់ខ្ពស់ ដល់បញ្ហាគណនេយ្យភាពពីលើចុះក្រោមនៅក្នុងសមាគម ។ កសិករភាគច្រើនក្នុងសហគមន៍ នៅតែគិតឃើញបែបបុរាណពីការចូលរួម ពោលគឺគ្រាន់តែទៅចូលរួមក្នុងការប្រជុំផ្សេងៗ និងបង់ថ្លៃប្រើទឹកស្រោចស្រពប៉ុណ្ណោះ ដោយគ្មានការលើកឡើងពីចំណុចព្រួយបារម្ភ រឺការទាមទារឱ្យមានដំណោះស្រាយអ្វីទេ ។

ទីពីរ កង្វះការផ្ដល់សិទ្ធិអំណាចឱ្យសហគមន៍ ធ្វើឱ្យសហគមន៍ពុំមានយន្តការជាផ្លូវការសំរាប់ទទួលបណ្ដឹងតវ៉ា ដូច្នេះហើយការយល់ច្រឡំពីគ្នាក៏កើនឡើងរវាងពួកកសិករ ហើយនឹងសមាគមជាតំណាងរបស់ខ្លួន ។ ក្នុងករណីសិក្សានេះ ជារឿយៗកសិករប្រើពាក្យចចាមអារាម រឺបញ្ឆិតបញ្ឆៀងដើម្បីតវ៉ាពីអ្នកដឹកនាំសមាគម និងចំណុចខ្វះខាតផ្សេងៗក្នុងបុគ្គលិកលក្ខណៈរបស់ពួកគេ ដែលខាងសមាគមយល់ថាជារឿងគួរឱ្យក្ដៅក្រហាយ ហើយភាគីទាំងពីរដែលត្រូវជិតស្និទ្ធនឹងគ្នា ក៏បែរជាកាន់តែចុះខ្សោយទំនាក់ទំនង ។ នៅក្នុងសហគមន៍ គេសង្កេតឃើញមានការមិនទុកចិត្តគ្នា និងស្មារតីរួមរួមគ្នាក៏រិតខ្សោយ ។ ប្រជាជនក្នុងមូលដ្ឋានមើលឃើញការតែងតាំងសមាជិកភាគច្រើនក្នុងក្រុមអ្នកប្រើប្រាស់ទឹកថាជាការប្រកាន់បក្សពួករបស់ថ្នាក់ដឹកនាំសមាគម ដែលបានដាក់បញ្ចូលសាច់ញាតិ និងមិត្តភក្តិខ្លួន ដើម្បីរកផលចំណេញ ។

ទីបី សហគមន៍ដែលមានស្ថាប័នខ្សោយដូចក្នុងករណីសិក្សានេះ អាចទទួលជោគជ័យ រឺបរាជ័យដោយសារជាសំខាន់របៀបដឹកនាំរបស់អ្នកដឹកនាំសំខាន់ៗ ជាពិសេសនៅពេលដែលរដ្ឋអំណាចមូលដ្ឋាន និងមន្ទីរក្រសួងជំនាញ មិនសូវបានពាក់ព័ន្ធនឹងការងាររបស់សមាគម និងជួយត្រួតពិនិត្យភាពពេញច្បាប់ និងប្រសិទ្ធភាពការងាររបស់សមាគម ។ ក្នុងករណីសិក្សានេះ ថ្នាក់ដឹកនាំសមាគមមានរបៀបដឹកនាំ ដូចជា មេកើយមិនចង់ចែករំលែកភារកិច្ច មិនធ្វើសេចក្ដីសំរេច ដោយផ្អែកលើការមូលមតិ ប៉ុន្តែច្រើនតែអនុវត្តតាមផែនការដែលខ្លួនឯងរៀបចំជាមុន ប្រើប្រាស់អង្គប្រជុំ និងសមាជិកបំរើការឯទៀតៗ ជាឈ្នាន់សំរាប់ការពារ និងអនុវត្តគំនិតខ្លួន ទុកចំណូលទាំងអស់នៅនឹងខ្លួនឯង ហើយសំរេចអារកាត់លើចំណាយទាំងអស់ដែលខ្លួនយល់ថា មានប្រយោជន៍សំរាប់សហគមន៍ ។ របៀបធ្វើការនេះ មាននិន្នាការគួរឱ្យបារម្ភ និងចោទបញ្ហាពីភាពពេញច្បាប់ និងចីរភាពនៃ CBNRM នៅក្នុងសហគមន៍ ។

ភាពជាម្ចាស់ ដែលជាកត្តាមួយសំខាន់បំផុតសំរាប់ជំរុញ CBNRM ក៏អនុវត្តមិនទាន់បានពេញលេញដែរ ។ គេអង្កេតឃើញមានភាពជាម្ចាស់ពីរប្រភេទនៅក្នុងករណីសិក្សា គឺអារម្មណ៍ជាម្ចាស់លើធនធាន និងអារម្មណ៍ជាម្ចាស់លើសមាគម FWUC ។ ក្នុងសហគមន៍ ភាពជាម្ចាស់លើធនធានអាចមើលឃើញតាមបែបបទប្រជាកសិករគោរព ភ្នំខ្សាច់ ដែលត្រូវបានកសាងឡើងនៅក្បែរស្ពាន ដោយប្រើប្រាក់កាសរបស់សហគមន៍ ដើម្បីជានិមិត្តរូបនៃបារមីសក្តិសិទ្ធិរបស់អាងទឹក ។ ប៉ុន្តែ ប្រជាកសិករមិនមានអារម្មណ៍ជាម្ចាស់លើសមាគម FWUC ទេ ដោយមើលឃើញថា គ្រាន់តែជាអំណាចគ្រប់គ្រងមួយស្រទាប់ទៀត និងជាអភិបាលកិច្ចមិនល្អតែប៉ុណ្ណោះ ។ ក្នុងការបោះឆ្នោតនៅឆ្នាំ២000 ពួកកសិករជាប់ពាក់ព័ន្ធមិនបានចូលរួមទាំងអស់គ្នាទេ ហើយតាំងពីពេលនោះ មកមានកសិករជាច្រើននាក់ទៀតបានចូលមកក្នុងសហគមន៍ ដោយមិនដែលមានឱកាសបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំរបស់ខ្លួនឡើយ ។

**បញ្ហាចោទពីរបៀបធ្វើការរបស់សមាគម**
**ឬថ្នាក់ដឹកនាំ ដែលមិនបានឱ្យសមាជិកពាក់ព័ន្ធចូលរួមទាំងអស់គ្នា**
**ក្នុងការងារធ្វើផែនការរបស់សមាគម**
**បានកាត់បន្ថយអារម្មណ៍ជាម្ចាស់ ហើយស្ថានភាពនេះ**
**បានគំរាមកំហែង ដល់ការចូលរួមនៅថ្នាក់មូលដ្ឋាន ។**

បញ្ហាចោទពីរបៀបធ្វើការរបស់សមាគម ឬថ្នាក់ដឹកនាំ ដែលមិនបានឱ្យសមាជិកពាក់ព័ន្ធចូលរួមទាំងអស់គ្នា ក្នុងការងារធ្វើផែនការរបស់សមាគម បានកាត់បន្ថយអារម្មណ៍ជាម្ចាស់ ហើយស្ថានភាពនេះ បានគំរាមកំហែង ដល់ការចូលរួមនៅថ្នាក់មូលដ្ឋាន ។ ដោយគ្មានអារម្មណ៍ជាម្ចាស់លើសមាគម ប្រជាកសិករមិនបានចាត់ទុកសមាគម ជាស្ថាប័នពេញច្បាប់សំរាប់គ្រប់គ្រងប្រព័ន្ធស្រោចស្រពឡើយ ។ ពួកគេយល់ថា ទឹកស្រោចស្រព គឺជាទ្រព្យសាធារណៈ ដូច្នេះមិនគួរស្ថិតក្រោមការគ្រប់គ្រងរបស់សមាគមជាក់លាក់ណាមួយទេ ឬក៏និយាយម្យ៉ាងទៀតថា គ្មានសមាគមណាអាចទាមទារកម្មសិទ្ធិលើប្រព័ន្ធស្រោចស្រព និងសម្រេចអារកាត់លើសិទ្ធិប្រើប្រាស់ និងថ្លៃសេវាលើធនធានទាំងនេះឡើយ ។ ចំពោះប្រជាកសិករ ការគ្រប់គ្រងធនធាន គឺជាភារកិច្ចនៃភ្នាក់ងាររបស់រដ្ឋ ហើយការពង្រឹងអនុវត្តច្បាប់ គឺជាភារកិច្ចរបស់ស្ថាប័ន ដូចជាខាងនគរបាល និងយោធាជាដើម ។ សហគមន៍ពីរដែលមានធនធាន និងមានប្រព័ន្ធធារាសាស្ត្រពីរនៅជាប់គ្នា និងនៅក្នុងដែនរងតែភ្លៀងតែមួយ ហាក់ដូចមិនព្រមទទួលស្គាល់ពីវត្តមាន និងតួនាទីរបស់ភាគីម្ខាងទៀតទេ ដូច្នេះសូម្បីតែសកម្មភាពតូចតាច ដូចជា កិច្ចចរចាគ្នាពីការប្រើទឹក ក៏រំពឹងថាត្រូវដោះស្រាយតាមរយៈរចនាសម្ព័ន្ធ អភិបាលកិច្ចនៅមូលដ្ឋានដែរ (ក្នុងករណីនេះ គឺតាមរយៈមេឃុំ) ។

ក្នុងករណីសិក្សានេះ ហាក់ដូចមានការតម្រង់ទិសមួយដែលអនុញ្ញាតឱ្យសមាគម FWUC (គឺមិនមែនសហគមន៍ទេ) ធ្វើការត្រួតត្រាលើធនធានដោយខ្លួនឯង ដោយគ្មាន ឬមានការគាំទ្រ/ការពិនិត្យតាមដានពីស្ថាប័នរដ្ឋ ។ មកដល់ពេលនេះ សមាគមបានបង្ហាញពីអសមត្ថភាពក្នុងការត្រួតត្រាលើធនធាន ដូចជាការត្រួតត្រាលើសិទ្ធិប្រើប្រាស់ជាដើម ។ ទោះបីសមាគមមានអាណត្តិគ្រប់គ្រងសិទ្ធិប្រើប្រាស់ក្ដី ប៉ុន្តែលទ្ធភាពរបស់សមាគមក្នុងការអនុវត្តសិទ្ធិនេះនៅទន់ខ្សោយណាស់ ។ Ostrom (១៩៩៩) បានលើកមតិថា ការគ្រប់គ្រងធនធានទ្រព្យរួមប្រកបដោយប្រសិទ្ធភាព ចាំបាច់ត្រូវមានលទ្ធភាពត្រួតត្រាលើសិទ្ធិប្រើប្រាស់ ព្រោះវាជាប់ទាក់ទងដោយផ្ទាល់ទៅដល់សុខុមាលភាព និងនៃធនធាន ព្រមទាំងប្រសិទ្ធភាពនៃការគ្រប់គ្រង ។

ប៉ុន្តែករណីនេះ មិនឃើញមានក្នុងករណីសិក្សាឡើយ ។ តាមរបាយការណ៍របស់មន្ទីរជំនាញខេត្ត ផ្ទៃគ្របដណ្តប់នៃប្រព័ន្ធធារាសាស្ត្រ ត្រូវបានពង្រីកធំហួសសមត្ថភាពរបស់ប្រព័ន្ធនោះច្រើនណាស់ ប៉ុន្តែគ្មានឃើញធ្វើអ្វីសោះដើម្បីដោះស្រាយបញ្ហានេះ ។ សមាជិកសមាគម ឬប្រជាកសិករ មិនបានយល់ដឹងច្បាស់ពីអាណត្តិរបស់សមាគមទេ ហើយបញ្ហានេះរឹតតែធ្ងន់ធ្ងរទៀតដោយ FWUC នាបច្ចុប្បន្ន បានធ្វើសកម្មភាពលើសពីភារកិច្ចពេញច្បាប់ ហើយប្រជាកសិករចេះតែចោទសួរពីភាពពេញច្បាប់របស់ FWUC ទោះបីកសិករភាគច្រើននៅតែបង់ថ្លៃសេវាផ្តល់ទឹកក្តី ។ កង្វះលទ្ធភាពត្រួតត្រាសិទ្ធិប្រើប្រាស់ បណ្តាលឱ្យមានវិសមភាពរវាងធនធាន និងករិតប្រើប្រាស់ ហើយវាប៉ះពាល់យ៉ាងខ្លាំងដល់ការអភិវឌ្ឍជីវភាពរយៈពេលវែងរបស់សហគមន៍ និងវត្តមានធនធានទៅអនាគត ។ កង្វះទឹក នៅពាក់កណ្តាល ឬនៅចុងរដូវដាំដុះគ្មានអ្វីប្លែកទេ ហើយនៅពេលខ្វះទឹក បទបញ្ញត្តិរបស់សហគមន៍ដែលទន់ខ្សោយស្រាប់នោះ ត្រូវបានបំភ្លេចចោលតែម្តង ហើយការប៉ះទង្គិចពាក្យសំដីរវាងកសិករលើបញ្ហាទឹក បានធ្វើឱ្យល្អក់កករដល់ទំនាក់ទំនងក្នុងសហគមន៍ ។ ជាមួយគ្នានោះ ក៏មានសំណង់ធារាសាស្ត្រនៅខ្សែទឹកខាងលើ ដែលមានដំណើរការប៉ះពាល់ដល់ CBNRM នៅក្នុងសហគមន៍សិក្សា ។

ដំណោះស្រាយ គឺអាចជាការបង្កើតយន្តការមួយសំរាប់ជួយអោយសហគមន៍ទាំងអស់ ដែលប្រើប្រាស់ទឹកក្នុងដែនរងទឹកភ្លៀងតែមួយ អាចចែករំលែកព័ត៌មាន ដើម្បីបានដឹងពីសកម្មភាពរបស់ភាគីនីមួយៗ ។ Kim & Öjendal (២០០៧) បានបញ្ជាក់ថា យន្តការនេះនៅឆ្ងាយពីការពិតខ្លាំងណាស់ ដោយសារកង្វះការយល់ដឹងពីតម្រូវការយន្តការ កង្វះធនធាន និងកង្វះអាណត្តិតាមផ្លូវច្បាប់ ។

## សេចក្តីបញ្ចប់

ករណីសិក្សាបង្ហាញថា អភិបាលកិច្ចលើទឹកស្រោចស្រពនៅមូលដ្ឋាននាពេលបច្ចុប្បន្ន គឺអនុវត្តតាមវិធីសាស្ត្រគ្រប់គ្រងធនធានធម្មជាតិផ្អែកលើសហគមន៍ (CBNRM) ក្នុងបរិបទនៃ វិមជ្ឈការក្នុងការគ្រប់គ្រងធនធានធម្មជាតិ (DNRM) ។ តាំងពីពេលរបបខ្មែរក្រហមបានដួលរលំមក រដ្ឋអំណាចមូលដ្ឋានជារឿយៗ អាចលើកសំណើដល់ថ្នាក់លើឱ្យផ្តល់ការគាំទ្រជាហិរញ្ញវត្ថុ ដើម្បីធ្វើវិនិយោគតែមួយលើក ជាសំណង់ធារាសាស្ត្រ ប៉ុន្តែក្រោយបានសាងសង់រួចរាល់ ខាងរដ្ឋអំណាចទាំងថ្នាក់មូលដ្ឋាន និងទាំងថ្នាក់លើ ច្រើនតែដកខ្លួនចេញបាត់ ធ្វើឱ្យសំណង់មិនអាចដំណើរការមានចីរភាព ។ វិធីសាស្ត្រ CBNRM ដូចកំពុងអនុវត្តសព្វថ្ងៃ អាចជួយបំពេញចន្លោះខ្វះខាតទាំងនេះបាន ពីព្រោះវាអាចឆ្លើយតបប្រសើរជាងទៅនឹងតម្រូវការនៅមូលដ្ឋាន ចាត់ចែងបញ្ហាបានឆាប់រហ័ស និងផ្តល់ដំណោះស្រាយអស់ចំណាយតិច និងសមស្របតាមបរិបទ ។ ប៉ុន្តែវិធីសាស្ត្រនេះអនុវត្តបានតិចនៅឡើយ ដោយសារយន្តការជំរុញទាំងបី គឺ ការចូលរួម ភាពជាម្ចាស់ និងការត្រួតត្រា មិនទាន់ដំណើរការបានពេញលេញ ។ លោក Carlson (២០០៣) បានលើកថា គេត្រូវធ្វើការបីយ៉ាង ដើម្បីប្រើប្រាស់អំណាចនៃយន្តការទាំងបី ។ ទីមួយ បទបញ្ញត្តិច្បាប់គួរផ្តល់សិទ្ធិអំណាចដល់សហគមន៍ ដោយកំណត់ទំហំសិទ្ធិរបស់សហគមន៍លើទ្រព្យរបស់សហគមន៍ ។ ទីពីរ ត្រូវធានាថាមានការគាំទ្រពីខាងក្រៅដ៏ល្អបំផុតដល់សមាគម និងសហគមន៍ ដូចជា ខាងផ្នែកហិរញ្ញវត្ថុ ការកសាងសមត្ថភាព និងជំនួយបច្ចេកទេស ។ ទីបី ត្រូវកសាងទំនុកចិត្តក្នុងសហគមន៍ និងរវាងសហគមន៍ និងរដ្ឋាភិបាល ។ ក្នុងការអនុវត្តរបស់សមាគម FWUC និងសហគមន៍ក្នុងករណីសិក្សាសមាសធាតុទាំងបីនេះនៅខ្វះខាត ហើយគេត្រូវដោះស្រាយរឿងនេះ ដើម្បីកែលំអអភិបាលកិច្ចនៅមូលដ្ឋានលើទឹកស្រោចស្រព ។

## ឯកសារយោង


Berkes, F. (1989), *Common property resources: Ecology and community-based sustainable development* (London: Belhaven Press)

Carlsson, L. (2003), "The Strategy of the Commons: History and Property Rights in Central Sweden", in, F. Berkes, J. Colding & E. Folke (eds.), *Navigating Social-Ecological Systems: Building Resilience for Complexity and Change* (New York: Cambridge University Press)

Hardin, G. (1968), "The tragedy of the commons", *Science*, 162, pp. 1243–1248

Kim S. & J. Öjendal (2007 ), *Where decentralisation meets democracy: Civil society, local government and accountability in Cambodia*, Working Paper 35 (Phnom Penh: CDRI)

Ostrom, E. (1990), *Governing the commons: The evolution of institutions for collective action* (New York: Cambridge University Press)

Ostrom, E. (1992), *Crafting Institutions for Self-Governing Irrigation Systems* (San Francisco: ICS Press)

Ostrom, E. (1999), "Institutional rational choice: An assessment of the institutional analysis and development framework", in P.A. Sabatier (ed.), *Theories of the Policy Process* (Boulder: Westview Press) pp. 35–71

Shaw-Lefevre, E.G. (1894), *English commons and forests: The story of the battle during the last thirty years for public rights over the commons and forests of England and Wales* (London: Cassel)

Yin R.K. (2003), *Applications of case study research* (London: Sage Publications)